# សុន្ទរកថាស្វាគមន៍
# ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន
# ក្នុងពិធីបើកសិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥

- *ជាបឋម ខ្ញុំបាទសូមគោរព* ***សម្តេចក្រឡាហោម ស ខេង*** *ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាទីគោរពដ៏ខ្ពង់ខ្ពស់!*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាគណៈអធិបតី ភ្ញៀវកិត្តិយស និងសមាជិក សមាជិកានៃអង្គសិក្ខាសាលាទាំងមូល ជាទីមេត្រី!*

ថ្ងៃនេះ ជាទិវាប្រកបដោយក្តីសោមនស្សរីករាយ និងមានកិត្តិយសក្រៃលែង ដោយបាន **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** អញ្ជើញជាអធិបតី ក្នុងពិធីបើកសិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យស្តីពី«**ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន**» ដែលត្រូវបានរៀបចំឡើង ក្រោមកិច្ចសហការរវាងក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងជាសាធារណៈ អំពីការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន សំដៅពង្រឹងប្រសិទ្ធភាពការងារ តាមរយៈការប្រគល់មុខងារទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក ក៏ដូចជា ការធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននេះពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ។

ក្នុងនាមគណៈកម្មការរៀបចំសិក្ខាសាលាផ្សព្វផ្សាយនេះ ខ្ញុំបាទសូមសម្តែងនូវគារវកិច្ចយ៉ាងកក់ក្តៅចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ហើយខ្ញុំបាទក៏សូមសម្តែងនូវការស្វាគមន៍ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានឆ្លៀតពេលដ៏មមាញឹក អញ្ជើញចូលរួមក្នុងសិក្ខាសាលាដ៏មានសារៈសំខាន់នេះ។

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមក្រសួងបរិស្ថាន ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារអន្តរក្រសួង ដែលបានរៀបចំអនុក្រឹត្យស្តីពី«ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន»នេះឡើង។ ជាមួយគ្នានេះដែរ ជំនួសមុខឱ្យក្រុមការងារអន្តរក្រសួង ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ «**មូលនិធិខុនរ៉ាដ អាឌិនណៅអ៊ែរ**» ដែលបានចូលរួមគាំទ្រជាថវិកាដល់ដំណើរការរៀបចំសិក្ខាសាលាផ្សព្វផ្សាយនេះ។

ខ្ញុំបាទសូមគោរពរាយការណ៍ជូនសម្តេច និងអង្គសិក្ខាសាលាទាំងមូលឱ្យបានជ្រាបថា ដោយមើលឃើញពីភាពចាំបាច់ ក្នុងការលើកកម្ពស់សោភ័ណភាព សណ្តាប់ធ្នាប់សាធារណៈ សុខមាលភាពសង្គម និងគុណភាពបរិស្ថាន នៅតាមបណ្តាទីប្រជុំជន នៅទូទាំងព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យស្តីពី«ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន»នេះ ដើម្បីជាត្រីវិស័យតម្រង់ទិស និងជាគោលការណ៍ណែនាំ សម្រាប់ដោះស្រាយបញ្ហាប្រឈមចំពោះមុខនៅក្នុងមូលដ្ឋាននីមួយៗ។

ជារួម យើងអាចនិយាយបានថា ការជួបជុំគ្នាថ្ងៃនេះជាលទ្ធផលនៃកិច្ចសហការរវាងក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន ទាំងក្នុងក្របខ័ណ្ឌច្បាប់ បច្ចេកទេស និងគោលនយោបាយ ហើយយើងក៏អាចចាត់ទុកសមិទ្ធផលថ្ងៃនេះ ជាការរួមចំណែកយ៉ាងសំខាន់ដល់ការអនុវត្ត«កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ» របស់រាជរដ្ឋាភិបាល។

*សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គសិក្ខាសាលាទាំងមូល ទីមេត្រី!*

ខ្ញុំបាទសូមគោរពរាយការណ៍ជូនអង្គពិធីទាំងមូលឱ្យបានជ្រាបថា ដោយមានការសម្របសម្រួលពីគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថានបានធ្វើការសិក្សាទៅលើក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា និងបានសិក្សាពីបទពិសោធការគ្រប់គ្រងសំរាម សំណល់រឹង នៅតាមបណ្តាប្រទេសមួយចំនួនលើសកលលោក ដើម្បីរៀបចំអនុក្រឹត្យនេះឡើង។

ចំពោះដំណើរការរៀបចំវិញ ក្រុមការងារអន្តរក្រសួងបានអនុវត្តតាមគោលការណ៍ប្រមូលផ្តុំគំនិតពីគ្រប់មជ្ឈដ្ឋាន ដោយបើកឱ្យមានការចូលរួមពីសំណាក់ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា តាមរយៈការរៀបចំឱ្យមានវេទិកាពិគ្រោះយោបល់យ៉ាងទូលំទូលាយ។

ជាងនេះទៅទៀត ក្រសួងមហាផ្ទៃនិងក្រសួងបរិស្ថានក៏បានរៀបចំកិច្ចប្រជុំអន្តរក្រសួងជាលក្ខណៈចង្អៀត ដោយមានការចូលរួមពីតំណាងក្រសួងយុត្តិធម៌ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍កម្ពុជា ដើម្បីពិនិត្យ និងកែសម្រួលខ្លឹមសារនៃសេចក្តីព្រាងចុងក្រោយ ដើម្បីធានាសង្គតិភាព ទាំងទិដ្ឋភាពបច្ចេកទេស ក្របខ័ណ្ឌគតិយុត្ត និងលក្ខខណ្ឌសមស្រប ដែលអាចអនុវត្តបាននៅក្នុងសង្គម។

ឆ្លើយតបនឹងគោលបំណង គោលដៅ និងខ្លឹមសារនៃអនុក្រឹត្យនេះ ក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថានក៏បានរៀបចំសារាចរអន្តរក្រសួងស្តីពីការអនុវត្តអនុក្រឹត្យនេះដើម្បីធានាការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកបដោយភាពរលូន ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ សារាចរអន្តរក្រសួងនេះក៏នឹងត្រូវផ្សព្វផ្សាយនៅក្នុងសិក្ខាសាលានេះផងដែរ។

ជាមួយគ្នានេះដែរ ក្រុមការងារក៏បានរៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួងរបស់ក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ស្តីពីការកំណត់កម្រៃអតិបរមានៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដែលជាមូលដ្ឋានគោល សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិកំណត់កម្រៃសេវាប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ឱ្យបានត្រឹមត្រូវនិងសមស្របទៅនឹងកម្រិតជីវភាពប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។ ក្រៅពីនេះ ក្រុមការងារក៏បានរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។ ជារួម សេចក្តីព្រាងទាំងពីរច្បាប់នេះ នឹងត្រូវដាក់ជូនអង្គសិក្ខាសាលាពិនិត្យ និងផ្តល់ពិគ្រោះយោបល់ ដើម្បីឱ្យខ្លឹមសារគោលនៃសេចក្តីព្រាងទាំងនេះ អាចឆ្លើយតបនឹងស្ថានភាពជាក់ស្តែងក្នុងសង្គម។

*សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គសិក្ខាសាលាទាំងមូល ជាទីគោរព!*

ទោះជាយ៉ាងណាក្តី ទន្ទឹមនឹងមោទនភាពលើសមិទ្ធផលដែលយើងសម្រេចបាននាពេលនេះ យើងក៏នៅប្រឈមនឹងបញ្ហាពាក់ព័ន្ធជាច្រើន ដែលរួមមាន ការផ្លាស់ប្តូរឥរិយាបទប្រជាពលរដ្ឋឱ្យចូលរួមទទួលខុសត្រូវ គុណភាពសេវាកម្មគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដែលឆ្លើយតបទៅនឹងកំរិតជីវភាពប្រជាពលរដ្ឋ និងការពង្រឹងការទទួលខុសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងការអនុវត្តមុខងារនេះ។

ក្នុងន័យនេះ ខ្ញុំបាទ ក្នុងនាមក្រសួងបរិស្ថាន សូមគោរពស្នើការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីសម្តេចក្រឡាហោម ដើម្បីឱ្យអង្គសិក្ខាសាលាទាំងមូល ចូលរួមពិភាក្សាលើការកំណត់កម្រៃអតិបរមានៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយផ្តោតលើតុល្យភាពរវាងគុណភាពសេវានិងកំរិតជីវភាពប្រជាពលរដ្ឋ និងការពារឧត្តមប្រយោជន៍សាធារណៈ ទាំងរបស់ប្រជាពលរដ្ឋ ប្រតិបត្តិករ និងអង្គភាពទទួលខុសត្រូវ ក៏ដូចជា ចូលរួមពិភាក្សាទៅលើបច្ចេកទេសនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយឈរលើស្មារតីម្ចាស់ការ និងភាពដែលអាចអនុវត្តបាន ក្នុងក្របខ័ណ្ឌនៃកិច្ចគាំពារបរិស្ថាន ស្របតាមទស្សនាទានស្តីពីការរស់នៅដោយចីរភាព។

ដោយហេតុថា ការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននេះ ទាមទានូវការគាំទ្រទាំងធនធាន និងបច្ចេកទេស ទើបរាជរដ្ឋាភិបាលបានផ្តល់ជូននូវកញ្ចប់ថវិកាសេវាអនាម័យបរិស្ថានចំនួន៥ពាន់លានរៀល និងបានផ្ទេរដល់រដ្ឋបាលក្រុងទាំង២៦ នាចុងត្រីមាសទី៣ ឆ្នាំ២០១៥នេះ ដែលរហូតមកដល់ពេលនេះមានក្រុងចំនួន១៧ ក្រុង បាននិងកំពុងអនុវត្ត ហើយក្រុងមួយចំនួនទៀតកំពុងបំពេញបែបបទលទ្ធកម្ម។

ម្យ៉ាងវិញទៀត ដើម្បីឱ្យការអនុវត្តមុខងារខាងលើស្របនឹងខ្លឹមសារនៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននេះ ខ្ញុំបាទសូមស្នើដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេស រដ្ឋបាលរាជធានីខេត្ត មេត្តាគាំទ្រនិងជួយសម្របសម្រួលការផ្ទេរមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅរដ្ឋបាលខណ្ឌ ក្រុង ស្រុក រួមទាំងធនធាន ដែលបាននិងកំពុងប្រើប្រាស់។ ជាងនេះទៅទៀត គឺសូមចូលរួមពិនិត្យពិភាក្សាកែសម្រួលកិច្ចសន្យាផ្តល់សេវាកម្មប្រមូល និងដឹកជញ្ជូន ដែលបាននិងកំពុងអនុវត្តឱ្យស្របតាមខ្លឹមសារនៃអនុក្រឹត្យនេះ។

ដើម្បីគាំទ្រដល់ដំណើរការនៃការកែសម្រួលកិច្ចសន្យា ក៏ដូចជា ការរៀបចំយន្តការនៃការប្រមូលនិងគ្រប់គ្រងចំណូលពីសេវាកម្ម ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ខ្ញុំបាទសូមស្នើសុំក្រុមការងារក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន មេត្តារួមគ្នាពិនិត្យលទ្ធភាពក្នុងការរៀបចំនិងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត សម្រាប់គាំទ្រដល់ដំណើរការផ្ទេរមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននេះ។

ជាថ្មីម្តងទៀត ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមការងារអន្តរក្រសួង ក៏ដូចជាថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមទាំងក្រសួងបរិស្ថាន ជាពិសេសក្រុមការងារ

នៃលេខាធិការដ្ឋានគ.ជ.អ.ប នៃក្រសួងមហាផ្ទៃ ដែលបានផ្តល់នូវកិច្ចសហការដ៏ល្អ ក្នុងការរៀបចំឯកសារ និងសិក្ខាសាលាដ៏មានសារៈសំខាន់នេះឡើង។

មុននឹងបញ្ចប់ ខ្ញុំបាទសូមអំពាវនាវដល់គ្រប់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍និងអ្នកពាក់ព័ន្ធទាំងអស់ សូមបន្តផ្តល់នូវការគាំទ្រ និងកិច្ចសហការ ដើម្បីឱ្យដំណើរការរៀបចំអនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្ត នានា ប្រព្រឹត្តទៅដោយរលូន និងអាចសម្រេចបានជោគជ័យក្នុងការងារគ្រប់គ្រងសំរាម និងសំណល់រឹង នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

ជាទីបញ្ចប់ ខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី សូមជួបតែនឹងពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមគោរពអញ្ជើញសម្តេចក្រឡាហោម មេត្តាឡើងថ្លែងសុន្ទរកថាបើក និងមានមតិសំណេះសំណាល

*សូមគោរពអញ្ជើញ សម្តេច!*

**សូមអរគុណ!**